**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :** ១៧២ **ក.ប** /ប្រ.ក

# ប្រកាស
# ស្តីពី
# ការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារ ដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១.-** គោលបំណង

ប្រកាសនេះមានគោលបំណងជម្រុញឲ្យនិយោជក នៃសហគ្រាស គ្រឹះស្ថានគ្រប់មុខវិជ្ជាជីវៈយកចិត្តទុកដាក់ជួយផ្តល់ចំណេះដឹងផ្នែកសុខភាពនិងសុវត្ថិភាពការងារដល់កម្មករនិយោជិត មុនពេលប្រើឲ្យធ្វើការ។

**ប្រការ២.-** និយមន័យពាក្យស័ព្ទសំខាន់ៗ

- និយោជក ជារូបវន្តបុគ្គល ឬនីតិបុគ្គល ជាសាធារណៈ ឬឯកជនទាំងអស់ដែលបង្កើតសហគ្រាស គ្រឹះស្ថានហើយប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ទោះមិនបានជាប់លាប់ក៏ដោយ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- គ្រឿងយន្ត ជាបណ្តុំនៃគ្រឿងចក្រមួយ ឬច្រើនផ្នែក ប្រើប្រាស់ដោយថាមពលមេកានិច ខ្យល់ ចំហាយ កំដៅ ឬអគ្គីសនី ដែលស្ថាបនាឡើង ដើម្បីជួយសម្រួលការងាររបស់មនុស្ស និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស ប្រសិនបើគ្មានការអប់រំបច្ចេកទេសសុវត្ថិភាពជាមុន ឬកង្វះរបាំងការពារសុវត្ថិភាព។ល។

- ហានិភ័យជីវសាស្ត្រ ជាហានិភ័យ ដែលបង្កឡើងដោយសំណល់វេជ្ជសាស្ត្រ ឬសំណាករបស់អតិសុខុមប្រាណ វីរុស ឬជាតិពុលមកពីប្រភពនៃជីវសាស្ត្រ ដែលនាំឲ្យប៉ះពាល់ដល់សរីរាង្គរស់ និងសុខភាពរបស់មនុស្ស។

- ការងារដាច់តែឯង ជាការងារទាំងឡាយណា ដែលមានមុខការតែឯកឯង ដោយប្រាស្រ័យទៅវិញទៅមកតាមរយៈវិទ្យុទាក់ទង ដើម្បីបញ្ជាការងារ។

- ការងារក្នុងមណ្ឌលហប់ ជាកន្លែងធ្វើការដែលតូចចង្អៀត និងមានមាត់រន្ធច្រកចូលតូចមិនអាចឲ្យមានការផ្លាស់ប្តូរខ្យល់អាកាសបានគ្រប់គ្រាន់ សម្រាប់ការដកដង្ហើម ដូចជាការងារក្នុងធុងធំ ស៊ីទែន អន្លង់ បាតនាវា ប្រឡាយបង្ហូរក្នុងដីបំពង់លូ អណ្តូង ផ្លូវក្នុងអណ្តូងរ៉ែ បន្ទប់ក្រោមដី ផលារាជ។ល។

- ការងារពេលយប់ ជាការងារដែលបានបំពេញរយៈពេលដប់មួយម៉ោងបន្តបន្ទាប់គ្នាយ៉ាងតិច ដោយក្នុងនោះត្រូវមានពេលពីម៉ោង២២ទៅម៉ោង៥ភ្លឺ ដោយអនុលោមតាមមាត្រា១៤៤ នៃច្បាប់ស្តីពីការងារ។

**ប្រការ៣.-** វិសាលភាព

និយោជក នៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ ស្តីពីការងារ មានកាតព្វកិច្ចអប់រំជាចាំបាច់ដល់កម្មករនិយោជិត និងតំណាងរបស់គេ អំពីអនាម័យ បច្ចេកទេសសន្តិសុខការងារ និងអំពីបញ្ហាសុខភាព ដែលមានទាក់ទងដល់កិច្ចការនៅតាមប៉ុស្តិ៍ការងារនីមួយៗ។

**ប្រការ៤.-** កាតព្វកិច្ចនិយោជក

និយោជក នៃសហគ្រាស គ្រឹះស្ថានត្រូវបង្ហាត់បង្រៀនដល់កម្មករនិយោជិត និងតំណាង អំពីហានិភ័យទាំងឡាយដែលអាចកើតមាននៅក្នុងសហគ្រាស គ្រឹះស្ថាន និងវិធានការការពារឲ្យមានប្រសិទ្ធភាព។

**ប្រការ៥.-** កម្មវិធីអប់រំបណ្តុះបណ្តាលទូទៅ

ឯកសារទាំងឡាយ ដែលយកមកបង្ហាត់បង្រៀនត្រូវបានគាត់តែង និងពិនិត្យសារជាថ្មីរៀងរាល់ឆ្នាំ។ ឯកសារទាំងនេះត្រូវបានរៀបរាប់យ៉ាងពិស្តារតាមចំណុចសំខាន់ៗខាងក្រោម៖

- ហានិភ័យរូបសាស្ត្រ



៦៥

- ហានិភ័យសារធាតុគីមី
- ហានិភ័យជីវសាស្ត្រ
- ហានិភ័យដែលទាក់ទងដល់ការប្រើប្រាស់គ្រឿងយន្ត
- ហានិភ័យនៃការលើកដាក់ទម្ងន់ដោយគ្រឿងចក្រ
- ហានិភ័យដែលទាក់ទងដល់ការធ្វើចរាចរគ្រឿងយន្តនៅក្នុងសហគ្រាស គ្រឹះស្ថាន
- ហានិភ័យអគ្គីសនី
- ហានិភ័យអគ្គីភ័យ ឬការផ្ទុះ
- ហានិភ័យនៃការធ្លាក់ពីទីខ្ពស់
- ហានិភ័យនៃការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម
- ហានិភ័យនៃការងារដាច់តែឯង
- ហានិភ័យនៃការងារក្នុងមណ្ឌលហាប់
- ហានិភ័យនៃការងារពេលយប់
- អនាម័យចំណីអាហារ អាហារូបត្ថម្ភ
- ហានិភ័យនៃឥរិយាបថបំពេញការងារ
- សុវត្ថិភាពអាគារ និងច្រកចេញចូល
- ភាពតានតឹងផ្លូវចិត្តដោយការងារ (ស្ត្រេសការងារ)
- និង ហានិភ័យផ្សេងៗទៀត ដែលចាំបាច់។

**ប្រការ៦**.- កម្មវិធីអប់រំ និងបណ្តុះបណ្តាលចំមុខជំនាញ

និយោជក ត្រូវធានាថាការអប់រំអនាម័យការងារ សុខភាព និងបច្ចេកទេសសន្តិសុខការងារនេះ បានធ្វើសម្រាប់កម្មករនិយោជិតម្នាក់ៗ។ ការអប់រំនេះ ត្រូវមានគុណប្រយោជន៍ និងមានភាពជាក់ច្បាស់ សម្រាប់ការអនុវត្តន៍តាមប៉ុស្តិ៍ការងារនីមួយៗរបស់កម្មករនិយោជិត។ និយោជក ត្រូវពន្យល់កម្មករនិយោជិតឲ្យយល់អំពី៖

- ហានិភ័យដែលអាចនឹងមាននៅប៉ុស្តិ៍ការងាររបស់គេ
- វិធានការការពារមានប្រសិទ្ធភាព និងបង្ហាញឲ្យបានច្បាស់ នូវឧបករណ៍ការពារទាំងឡាយដែលមាន
- កាយវិការ អាកប្បកិរិយានៅពេលមានអាសន្ន និងនៅពេលជួយសង្គ្រោះគ្នា។

និយោជកត្រូវអប់រំកម្មករនិយោជិត និងតំណាងរបស់គេនៅពេល៖

- ចូលធ្វើការដំបូង
- ប្តូរប៉ុស្តិ៍ការងារ
- ប្តូរបច្ចេកទេសផលិត ប្តូរគ្រឿងយន្ត ការបញ្ចូលសារធាតុគីមីថ្មី

- ប្តូរប្រព័ន្ធខ្សែចង្វាក់ផលិតកម្ម
- កម្មករនិយោជិតបានឈប់សម្រាកការងាររយៈពេលយូរ (លើសពីមួយខែ)។

ការអប់រំនេះត្រូវធ្វើដោយអ្នកបច្ចេកទេសពិតប្រាកដ និងធ្វើក្នុងម៉ោងធ្វើការ ហើយកម្មករនិយោជិត ដែលជាសិក្ខាកាមត្រូវបានទទួលប្រាក់ឈ្នួលធម្មតា។

**ប្រការ៧.-** និយោជក ក៏ត្រូវផ្តល់ការអប់រំ អនាម័យការងារ សុខភាព និងបច្ចេកទេសសន្តិសុខការងារនេះទៅតាមមុខជំនាញ ឬតាមហានិភ័យចាំបាច់ផងដែរ ដល់កម្មករនិយោជិត និងតំណាងដែលបានចូលបម្រើការងារក្នុងសហគ្រាស គ្រឹះស្ថានរបស់ខ្លួនមុនប្រកាសនេះចូលជាធរមាន។

**ប្រការ៨.-** បទប្បញ្ញត្តិ នៃប្រការទាំងឡាយខាងលើនៃប្រកាសនេះ មិនជំទាស់ទៅនឹងបទប្បញ្ញត្តិពិសេស នៃប្រកាសផ្សេងដទៃទៀតឡើយ។

**ប្រការ៩.-** ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

**ប្រការ១០.-** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**វង សុត**

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីសុខ អាន
-ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គ្រប់ក្រសួងពាក់ព័ន្ធ
-សហភាពសហព័ន្ធសហជីព
"ដើម្បីជូនជ្រាប"
-សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានការងារ
"ដើម្បីផ្សព្វផ្សាយនិងអនុវត្ត"
-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
"ដើម្បីមុខការ"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍
"ដើម្បីជួយផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃប្រកាសលេខ ១៧៦ ក.ប/ប្រ.ក**

ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣

## សេចក្តីពន្យល់ពាក្យបច្ចេកទេស

| ពាក្យខ្មែរ | ជាភាសាអង់គ្លេស | សេចក្តីពន្យល់ |
|---|---|---|
| ហានិភ័យ | Risk | គ្រោះថ្នាក់ ផលអាក្រក់ ដែលអាចកើតមាន |
| សារធាតុគីមី | Chemical | វិទ្យាសាស្ត្រ ដែលសិក្សាអំពីទម្រង់លក្ខណៈសមាសភាព និងបម្លែង នៃអង្គធាតុដែលត្រូវបានប្រើប្រាស់ជាវត្ថុធាតុដើម |
| រូបសាស្ត្រ | Physical | សំណុំវិទ្យាសាស្ត្រដែលសិក្សាអំពីលក្ខណៈរូបនៃរូបធាតុ (រឹង រាវ ឧស្ម័ន) |
| ជីវសាស្ត្រ | Biological | វិជ្ជា ឬគម្ពីរក្បួនខ្នាតចែងអំពីជីវិតមនុស្ស សត្វនិងរុក្ខជាតិ |
| មណ្ឌលហាប់ | Confine space | ទីកន្លែង មានមាត់រន្ធច្រកចូលតូចមិនអាចឲ្យមានការផ្លាស់ប្តូរខ្យល់អាកាសបានគ្រប់គ្រាន់ ឬកង្វះអុកស៊ីហ្សែនសម្រាប់ការដកដង្ហើម ដូចជាការងារក្នុងធុងធំ ស៊ីទែន អន្លង់ បាតនាវា ប្រឡាយបង្ហូរក្នុងដី បំពង់លូ អណ្តូងផ្លូវក្នុង អណ្តូងរ៉ែ បន្ទប់ក្រោមដី ផលារាជ |
| ឥរិយាបថបំពេញការងារ | Ergonomic | ការរៀបចំប៉ុស្តិ៍ការងារ ការជ្រើសរើសទីតាំងការងារ រួមទាំងសម្ភារៈ ដែលតម្រូវទៅនឹងការបំពេញការងារ សិរីរសាស្ត្រ ចិត្តវិជ្ជា និងសមត្ថភាពរបស់មនុស្ស |
| គ្រឿងយន្ត | Machinery | ជាបណ្តុំនៃគ្រឿងចក្រមួយ ឬច្រើនផ្នែក ប្រើប្រាស់ដោយថាមពលមេកានិច ខ្យល់ ចំហាយ កំដៅ ឬអគ្គីសនី ដែលស្ថាបនាឡើង ដើម្បីជួយសម្រួលការងារ របស់មនុស្ស និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស ប្រសិនបើគ្មានការអប់រំបច្ចេកទេស សុវត្ថិភាពជាមុន ឬកង្វះរបាំងការពារសុវត្ថិភាព |

| | | |
|---|---|---|
| អនាម័យចំណីអាហារ | Food Hygiene | ការរក្សាទុកចំណីអាហារប្រកបដោយសុវត្ថិភាព ដើម្បីបង្ការកុំឲ្យមានភ្នាក់ងារចម្លងរោគ |
| អាហារូបត្ថម្ភ | Nutrition | អាហារ ដែលសម្បូរទៅដោយជីវជាតិប្រូតេអ៊ីន ដូចជាបន្លែ ត្រី សាច់ ផ្លែឈើ ក្នុងការជួយទំនុកបម្រុងរាងកាយរបស់មនុស្ស |
| ស្រ្តេសការងារ | Stress at Work | ភាពតានតឹងផ្លូវអារម្មណ៍ឬប្រព័ន្ធប្រសាទដែលបណ្តាលមកពី ការធ្វើការហួសប្រមាណ ការស្តីបន្ទោសពីអ្នកគ្រប់គ្រង ការបន្ថែមម៉ោងហួសកំណត់។ល។ |
| ផលារាជ | Silo | ធុងធំ បញ្ឈរខ្ពស់ ដែលប្រើសម្រាប់ស្តុកគ្រាប់ធញ្ញជាតិផ្កាប់មេស្រាបៀរ ឬសម្រាប់លាយបេតុងស្វ័យប្រវត្តិ |